**ព្រឹទ្ធសភា**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
## ស្ដីពី
## លទ្ធផលការងាររបស់ព្រឹទ្ធសភា
## ប្រចាំខែមេសា ឆ្នាំ២០១៦

*នៅក្នុងខែមេសា ឆ្នាំ២០១៦ នេះព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ:*

**១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១ សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា ឬានៈ**

*-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក*

*-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីថ្វាយព្រះពរសង្ក្រាន្តឆ្នាំថ្មីថ្វាយ* ***ព្រះករុណា ព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី*** *ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា*

*-អនុញ្ញាតឲ្យឯកឧត្ដម* Chen Miner *លេខាធិការគណៈកម្មាធិការខេត្ត* Guizhou *នៃបក្សកុម្មុយនីសចិន ចូលជួបសម្ដែងការគួរសម និងសវនាការ*

*-អញ្ជើញជាអធិបតីក្នុងពិធីបង្សុកូលឧទ្ទិសកុសលជូន* ***សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម*** *និង* ***លោកជំទាវ ញ៉ែម សឿន ជា ស៊ីម*** *ស្ថិតនៅភូមិកន្ទែងជ្រៅ ឃុំក្រពៅ ស្រុកកំចាយមារ ខេត្តព្រៃវែង*

*-អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធ និងឆ្លងសមិទ្ធផលនានា ក្នុងវត្តអង្គក្រឡាញ់ ភូមិសាលាគ្រួស ឃុំព្រះនិព្វាន ស្រុកគងពិសី ខេត្តកំពង់ស្ពឺ*

*-អញ្ជើញក្នុងពិធីបង្សុកូលឧទ្ទិសកុសលជូន បុព្វការីជន ញាតិការទាំងប្រាំពីរសណ្ដាន ស្ថិតនៅភូមិកណ្ដាលកោះ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម*

*-អញ្ជើញចុះជួបសំណេះសំណាលអ្នកគ្រប់គ្រង និងក្រុមកម្មករ នៃកសិដ្ឋានចិញ្ចឹមមាន់ ស៊ុន គីមឡេង ស្ថិតនៅក្នុងភូមិរើងពើង ឃុំស្គុះ និងជួបសំណេះសំណាល*



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446 E-mail: oum_sarith@camnet.com.kh

ជាមួយអាជ្ញាធរដែនដី និងក្រុមប្រឹក្សាឃុំធម្មតាអរ នៅស្រុកក្ដីស្រួច ខេត្តកំពង់ស្ពឺ ព្រមទាំងបានអញ្ជើញចុះពិនិត្យទ្វារទឹក០២កន្លែង នៃទំនប់អាងថ្មពួក និងប្រឡាយមួយខ្សែប្រវែង២១៥០ម៉ែត្រ ដែលអាចនាំទឹកពីប្រឡាយមេទំនប់អាងថ្មពួកទៅភូមិ៥ ក្នុងភូមិធម្មតាអរ និងទៅភូមិ២ ក្នុងឃុំមហាសាំងដែលសម្ដេចឧបត្ថម្ភថវិកាចំនួន១២៧៥៨ដុល្លារអាមេរិកសម្រាប់ការជួសជុល ស្ពាន និងពង្រីកប្រឡាយខាងលើនេះ

-អញ្ជើញចុះជួបសំណេះសំណាលជាមួយអាជ្ញាធរ និងក្រុមប្រឹក្សាសង្កាត់និរោធន៍ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ

-អញ្ជើញនាំបច្ច័យសម្រាប់ការកសាងសមិទ្ធផលក្នុងវត្តចំនួន៨០លានរៀល ប្រគេនព្រះគ្រូចៅអធិការវត្ត និងគណៈកម្មការអាចារ្យវត្តជេតពន ហៅវត្តវាលស្បូវ ស្ថិតក្នុងសង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ

-អញ្ជើញសាកសួរសុខទុក្ខ ឯកឧត្តម **រ៉ាស៊ីម សំរិទ្ធ** ទីប្រឹក្សារាជរដ្ឋាភិបាលដែលកំពុងមានជំងឺ សម្រាកព្យាបាលនៅឯគេហដ្ឋាន ស្ថិតនៅសង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ

-អញ្ជើញចូលរួមរំលែកទុក្ខក្រុមគ្រួសារសពឧបាសិកា **ឈិត តើ** ប្រជាជនមានទីលំនៅទឹកល្អក់៣ ខណ្ឌទួលគោក

-ពិនិត្យ ផ្ដល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៩៣ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៣២ច្បាប់ ។

**១.២.ឯកឧត្តម នៃ ប៉ៃណា អនុប្រធានទី១ព្រឹទ្ធសភា បាន** :

-ពិនិត្យ ផ្ដល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន០៥ច្បាប់ និងជ្រាបជាព័ត៌មានចំនួន០៩ច្បាប់ ។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន** :

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីថ្វាយព្រះពរសង្ក្រាន្តឆ្នាំថ្មីថ្វាយ**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញចូលរួមក្នុងពិធីសូត្រមន្តឧទ្ទិសកុសលជូនវិញ្ញាណក្ខន្ធ**សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** និងលោកជំទាវ នៅភូមិកន្ទែងជ្រៅ ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង

-អញ្ជើញជាអធិបតីក្នុងពិធីសូត្រមន្តអបអរសាទរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលជាមួយសហជីព កម្មករ និយោជិត និងតំណាងមន្ត្រីរាជការ គ្រូបង្រៀន អបអរសាទរបុណ្យចូលឆ្នាំថ្មី និងទិវាពលកម្មអន្តរជាតិ ០១ឧសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅសាលមហោស្រពកោះពេជ្រ

-អញ្ជើញចូលរួមអបអរសាទរពិធីប្រគល់ពានរង្វាន់សន្តិភាព និងការអភិវឌ្ឍជូន **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា

-អញ្ជើញជាអធិបតីក្នុងពិធីបំពាក់គ្រឿងឥស្សរិយយសជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អញ្ជើញជាអធិបតីថ្ងៃងសុន្ទរកថាបើកវេទិកាភូមិភាគ១ស្តីពី " ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ការអភិវឌ្ឍសង្កាត់ ខណ្ឌ និងភូមិមានសុវត្ថិភាព" នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា

-អញ្ជើញជាអធិបតីក្នុងពិធីប្រគេនភ្លើងបូជាព្រះសព **ព្រះព្រហ្មធម្ម ស៊ីវ គីមសន** ព្រះរាជាគណៈថ្នាក់កិត្តិយស និងជាទីប្រឹក្សាផ្ទាល់សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី **ទេព វង្ស** នៅវត្តម្រំខាងជើង ខេត្តកំពង់ស្ពឺ

-អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការភោជនីយដ្ឋាន **បុងជូ ខេមបូឌា** ភ្នំពេញ

-អញ្ជើញនាំយកទេយ្យទានទៅប្រគេនព្រះសង្ឃ ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ នៅវត្តប្រាំបីមុំ ឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ

-អញ្ជើញនាំយកទេយ្យទានទៅប្រគេនព្រះសង្ឃ និងចែកអំណោយជូនប្រជាពលរដ្ឋក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ នៅឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់

-អញ្ជើញជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំក្នុងឱកាសដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់ឯកឧត្តមទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅឃុំព្រែកឫស្សី ស្រុកល្វាឯម ខេត្តកណ្តាល

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៧២ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២៥ច្បាប់ ។

**២. សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក** :

ពិនិត្យ និងសម្រេចបញ្ជូនសេចក្តីព្រាងច្បាប់ចំនួន០១ ទៅគណៈកម្មការជំនាញ និងទៅក្នុងរបៀបវារៈប្រជុំពេញអង្គព្រឹទ្ធសភា៖

១.ពិនិត្យ និងសម្រេចសំណើរបស់គណៈកម្មការទី៨ ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពីសហជីព

២.ពិនិត្យ និងសម្រេចសំណើលេខ:០៦/១៦ល.គ.គ.ក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ របស់គណបក្សប្រជាជនកម្ពុជា និងសំណើលេខ០០៩/១៦គ.ស.រ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ របស់គណបក្ស សមរង្ស៊ី

៣.កំណត់របៀបវារៈ និងកាលបរិច្ឆេទបន្តសម័យប្រជុំលើកទី៨ ព្រឹទ្ធសភា នីតិកាលទី៣ ។

**៣.សម័យប្រជុំពេញអង្គចំនួន០១លើក** :

១.ប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី

២.ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីសហជីព ។

**៤.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងខែមេសានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម :

**៤.១. មុខងារនីតិកម្ម**

-គណៈកម្មការជំនាញបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយនឹងតំណាងក្រសួងដើម្បីពិនិត្យ និងសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពីសហជីព ។

**៤.២. មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងចំនួន១៣ករណី ធ្វើលិខិតអន្តរាគមន៍ទៅស្ថាប័នមានសមត្ថកិច្ចដោះស្រាយចំនួន១៦ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងបានចំនួន១៧ករណី ទទួលពាក្យបណ្តឹងជូនជ្រាបចំនួន០២ករណី និងតម្កល់ទុកមិនចាត់ការចំនួន០២ករណី

-ក្រុមសមាជិកាព្រឹទ្ធសភាប្រចាំភូមិភាគទី១ បានរៀបចំវេទិកាថ្នាក់ស្រុកស្តីពីការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលផ្តោតលើប្រធានបទ "**ការផ្តល់សេវាសា**

ធារណៈជូនប្រជាពលរដ្ឋ ការអភិវឌ្ឍស្រុក -ខណ្ឌ និងភូមិ -សង្កាត់មានសុវត្ថិភាព " នៅរាជធានីភ្នំពេញ

-រៀបចំសិក្ខាសាលាស្តីពី"ទស្សនវិស័យ នៃភាសាបារាំងនៅកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា

-ចូលរួមសន្និសីទតំបន់ " ប្រទេសកម្ពុជា និងអាស៊ាន ការគ្រប់គ្រងកាលានុវត្តភាព និងការប្រឈមលើសពីឆ្នាំ២០១៥"

-ចូលរួមសិក្ខាសាលាស្តីពី " សន្តិសុខប្រព័ន្ធព័ត៌មានវិទ្យា " " ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងថវិកាជាតិ " និង "សង្គ្រាមលោកលើកទី៣ក្នុងភាពស្ងៀមស្ងាត់ "

-បទឧទ្ទេសនាមស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធព្រឹទ្ធសភា ជូនដល់សិក្ខាកាមវគ្គបំប៉ននាយទាហានជាន់ខ្ពស់កងរាជអាវុធហត្ថថ្នាក់ឧត្តមសេនីយ៍ចំនួន៣០នាក់

-ចូលរួមជាគណៈអធិបតីបើក និងបិទកម្មវិធីនៃវេទិកាសន្ទនាពិសេសទាក់ទងទៅនឹងវិស័យសាសនានៅវិទ្យាស្ថានCKCC

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ ប្រជុំកំណត់កម្មវិធី និងពិនិត្យគម្រោងចុះសិក្សាស្រាវជ្រាវក្នុងឆ្នាំ២០១៦

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ ប្រជុំពិនិត្យគម្រោងរៀបចំវេទិកាថ្នាក់ខេត្តនៅខេត្តបន្ទាយមានជ័យ

-ប្រជុំផ្ទៃក្នុងគណៈកម្មការអំពីគម្រោងទស្សនកិច្ចសិក្សានៅសភានៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

-ប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យលទ្ធផលនៃការចុះស្រាវជ្រាវជាក់ស្តែងបន្ថែមជាមួយអាជ្ញាធរភូមិ-ឃុំ និងប្រជាពលរដ្ឋខេត្តកំពត

-ប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យ និងឲ្យយោបល់លើឯកសារស្រាវជ្រាវស្តីពីហេតុផលដែលនាំឲ្យមានការលំបាកក្នុងការអនុវត្តក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីក្នុងបរិបទនៃអាពាហ៍ពិពាហ៍ និងគ្រួសារ និងការអនុវត្តកិច្ចសន្យាសំខាន់ៗ និងពិនិត្យលើការស្នើសុំបង្ហោះឯកសារស្រាវជ្រាវស្តីពីការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិលើគេហទំព័ររបស់វិទ្យាស្ថានសភាកម្ពុជា (PIC)

-ប្រជុំពិភាក្សាការងារជាមួយថ្នាក់ដឹកនាំ និងអាជ្ញាធរពាក់ព័ន្ធនៃខេត្តកំពត ដើម្បី

ត្រៀមរៀបចំវេទិកាក្នុងភូមិភាគទី៥ នាពេលខាងមុខ

-ប្រជុំជាមួយក្រុមការងារចុះសិក្សាស្រាវជ្រាវប្រមូលព័ត៌មានទាក់ទងបញ្ហាប្រឈម និងសំណូមពររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ របស់ខេត្តបន្ទាយមានជ័យ

-ជួបពិភាក្សាការងារជាមួយលោកបណ្ឌិត **ហាលមីន តុនស្មិត** ប្រធានអង្គការអន្តរជាតិ BLI និងសហការីរបស់លោកស្តីពីវិស័យការងារមនុស្សធម៌

-ជួបពិភាក្សាការងារជាមួយលោក **ហាខាន់ អាតាសឺវ៉** នាយកវិទ្យាស្ថានសន្ទនាមេគង្គ និងលោក **អេចជី គីលីក** នាយកសាលាហ្សាម៉ាន់

-ជួបសវនាការជាមួយឯកឧត្តម **អ៊ីល ហ៊ាលកេមាលតុង** ឯកអគ្គរដ្ឋទូតតួកគីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងសហការី

-អនុញ្ញាតឲ្យលោក **យ៉ែម សង្ហាវិចិត្រ** ប្រធាននាយកដ្ឋានប្រាក់បញ្ញើនៃធនាគារភ្នំពេញពាណិជ្ជ និងលោក **ទី ឧត្តមវាសនា** នាយកសាខាខណ្ឌច្បារអំពៅ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារមួយចំនួនពាក់ព័ន្ធទៅនឹងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា

-អនុញ្ញាតឲ្យលោក **ដារ៉ារិទ្ធ គឹមយាត** ប្រធានវិទ្យាស្ថានសភាកម្ពុជា (PIC) ជួបពិភាក្សាអំពីគម្រោងរៀបចំសិក្ខាសាលាតំបន់ស្តីពី " បញ្ហាប្រឈមក្នុងការគ្រប់គ្រងពលករ ទេសន្តប្រវេសន៍នៅអាស៊ាន "

-អនុញ្ញាតឲ្យតំណាងវិនិយោគគិនក្នុងស្រុកចូលជួបសម្តែងការគួរសម និងពិភាក្សាការងារមួយចំនួនពាក់ព័ន្ធទៅនឹងវិស័យវិនិយោគនៅកម្ពុជា

សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេស ចំនួន១២៣លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ - សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗ សរុបចំនួន៥១លើក។

### ៤.៣ មុខងារព័ត៌មាន

-អញ្ជើញចុះបេសកកម្មដើម្បីសិក្សាស្វែងយល់អំពីការអនុវត្តសិទ្ធិមនុស្ស និងការ

ដោះស្រាយពាក្យបណ្ដឹងរបស់ថ្នាក់ក្រោមជាតិ នៅខេត្តស្វាយរៀង និងខេត្តត្បូងឃ្មុំ

-អញ្ជើញចុះបេសកកម្មដើម្បីសិក្សាស្វែងយល់អំពីការអនុវត្តច្បាប់វឌ្ឍនភាពសំខាន់ៗ និងបញ្ហាប្រឈមនានាដែលពាក់ព័ន្ធជាមួយវិស័យអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ នៅខេត្តមណ្ឌលគិរី រតនគិរី និងខេត្តស្ទឹងត្រែង។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-ឯកឧត្តម **គង់ សារាជ** ឯកឧត្តម **ម៉ាន់ ឈឿន** ឯកឧត្តម **ម៉ែន ស៊ីផាន់** និងលោកជំទាវ **ឡាយ បូនី** អញ្ជើញទស្សនកិច្ចសិក្សាស្វែងយល់អំពី " បញ្ហាប្រឈម និងបទពិសោធន៍ល្អៗក្នុងការអនុវត្តមុខងារតំណាង និងមុខងារត្រួតពិនិត្យរបស់សភាបារាំង " នៅសាធារណរដ្ឋបារាំង

-ឯកឧត្តម **ជា ជេដ្ឋ** ឯកឧត្តម **យ៉ង់ សែម** និងឯកឧត្តម **ចាន់ ណារ៉េត** បានអញ្ជើញចូលរួមកិច្ចប្រជុំស្ដីពី " ភាពជាដៃគូសភាអាស៊ី-អឺរ៉ុបលើកទី៩ " នៅទីក្រុងអ៊ូឡង់បាទ័រ ប្រទេសម៉ុងហ្គោលី

-ឯកឧត្តម **ម៉ុង ឫទ្ធី** បានអញ្ជើញទស្សនកិច្ចសិក្សា និងជួបពិភាក្សាការងារជាមួយស្ថាប័នពាក់ព័ន្ធលើវិស័យអភិវឌ្ឍន៍ជនបទ និងកសិកម្ម នៅសាធារណរដ្ឋកូរ៉េ

-ឯកឧត្តម **យ៉ង់ សែម** និងឯកឧត្តម **ទាវ វណ្ណុល** បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំគណៈកម្មការនយោបាយនៃសភាប្រើប្រាស់ភាសាបារាំង (APF) នៅទីក្រុងញូវយ៉ក នៃសហរដ្ឋអាមេរិក

-ឯកឧត្តម **ឈិត គឹមយាត** និងលោកជំទាវ **កែវ ម៉ាលី** បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីប្រគល់ពានរង្វាន់ ជូនដល់សហគ្រិនស្មោះត្រង់អាស៊ីប៉ាស៊ីហ្វិកលើកទី១៤ នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី

-លោកជំទាវ **ពុំ ស៊ីចាន់** និងលោកជំទាវ **ថាក់ ឡានី** បានអញ្ជើញចូលរួមទស្សនកិច្ចសន្ទនាស្វែងយល់ពីការអភិវឌ្ឍស្ថានភាពសិទ្ធិមនុស្ស នៅទីក្រុងស្តុកខូម ប្រទេសស៊ុយអែត។៕

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៦

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)